HealthPartners®

# ព័ត៌មានរបស់អ្នក
# សិទ្ធិរបស់អ្នក
# ភាពទទួលខុសត្រូវរបស់យើង

## **កំណត់សម្គាល់នៃការអនុវត្តន៍ភាពឯកជន**
សម្រាប់អង្គការដែលជាផ្នែកនៃ
HealthPartners ។

កំណត់សម្គាល់នេះពណ៌នាពីរបៀបដែលព័ត៌មានសុខភាពរបស់អ្នក
អាចត្រូវបានប្រើប្រាស់ និងបង្ហាញ និងរបៀបដែលអ្នកអាចទទួល
បានព័ត៌មាននេះ ។ សូមពិនិត្យមើលឲ្យបានប្រុងប្រយ័ត្ន
**មានប្រសិទ្ធភាពនៅថ្ងៃទី 17 ខែវិច្ឆិកា ឆ្នាំ 2018**

## ការសង្ខេប

បេសកកម្មរបស់យើងគឺធ្វើឲ្យប្រសើរឡើងនូវសុខភាព និងសុខុមាលភាពនៃភាពជាដៃគូជាមួយសមាជិកយើង អ្នកជម្ងឺ និងសហគមន៍ ។ យើងចង់ឲ្យអ្នកមានអារម្មណ៍គាំទ្រ និងទទួលបានព័ត៌មានក្នុងការថែទាំ និងការធានារ៉ាប់រងរបស់អ្នក ។ វាមិនរាប់បញ្ចូលទាំងការពន្យល់ពីរបៀបដែលយើងប្រើប្រាស់ និងគ្រប់គ្រងព័ត៌មានរបស់អ្នក និងសិទ្ធិរបស់អ្នក និងជម្រើសទាក់ទងនឹងព័ត៌មាននោះ ។

ភាពឯកជនគឺជាប្រធានបទដ៏ស្មុគស្មាញមួយ ។ យើងដឹងថា វាអាចមានការភាន់ច្រលំ ជាពិសេសពេលដែលមានច្បាប់រដ្ឋ និងច្បាប់សហព័ន្ធចូលមកជាមួយ ។ យើងគោរពចំពោះការផ្តល់ទំនុកចិត្តមកលើយើង ដោយជ្រើសរើសយើងសម្រាប់ការព្យាបាល ការថែទាំ និងការធានារ៉ាប់រងរបស់អ្នក ។ យើងសង្ឃឹមថា ការសង្ខេបនៃសិទ្ធិ និងជម្រើសរបស់អ្នក និងភាពទទួលខុសត្រូវរបស់យើងសម្រាប់របៀបដែលយើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នក ជួយអ្នកឲ្យយល់ពីរបៀបដែលយើងធ្វើតាមច្បាប់ និងគោរពទំនុកចិត្តរបស់អ្នក ។

### ព័ត៌មានរបស់អ្នក

នៅក្នុងកំណត់សម្គាល់នេះ ពេលដែលយើងប្រើប្រាស់ "ព័ត៌មានរបស់អ្នក" គឺយើងសំដៅទៅព័ត៌មានដែលកំណត់ពីខ្លួនអ្នក ជាសមា-ជិកថ្មីឬចាស់នៃគម្រោងសុខភាព និងទាក់ទងពីសុខភាពឬស្ថានភាពរបស់អ្នក សេវាកម្មថែទាំសុខភាពរបស់អ្នក ការបង់ប្រាក់ ឬការធានារ៉ាប់រងសម្រាប់សេវាកម្មទាំងនោះ ។ វារាប់បញ្ចូលទាំងព័ត៌មានទាមទារនិងធានារ៉ាប់រង និងព័ត៌មានសុខភាព ដូចជាការធ្វើរោគវិនិច្ឆ័យ និងសេវាកម្មដែលអ្នកបានទទួល ។ វារាប់បញ្ចូលទាំងព័ត៌មានប្រជាសាស្ត្រ ដូចជាឈ្មោះរបស់អ្នក អាសយដ្ឋាន លេខទូរស័ព្ទ និងថ្ងៃខែឆ្នាំកំណើត ។

## សិទ្ធិរបស់អ្នកជាអ្នកជម្ងឺរបស់យើង

**សម្រាប់ព័ត៌មាន និងភាពឯកជនរបស់អ្នក អ្នកមានសិទ្ធិសំខាន់ក្រោមច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ ។** ផ្នែកនេះនឹងពន្យល់ពីសិទ្ធិទាំងនោះ ។ សាកសួរពួកយើងអំពីវា និងពួកយើងអាចពន្យល់ពីដំណើរការ រួមទាំងបើអ្នកត្រូវការដាក់សំណើរបស់អ្នកជាលាយលក្ខណ៍អក្សរ ។

**អ្នកមានសិទ្ធិក្នុងការ ៖**

### ទទួលបានច្បាប់ចម្លងព័ត៌មានរបស់អ្នកជាអេឡិចត្រូនិច ឬជាក្រដាស

- អ្នកអាចសុំមើល ឬទទួលបានច្បាប់ចម្លងព័ត៌មានរបស់អ្នកជាអេឡិចត្រូនិច ឬជាក្រដាស ។
- យើងនឹងផ្តល់នូវច្បាប់ចម្លង ឬការសង្ខេបព័ត៌មានរបស់អ្នកលឿនបំផុតតាមដែលអាចធ្វើបាន ។
- បើមានកំណត់ត្រាដែលយើងមិនអាចចែករំលែក ឬបើយើងត្រូវបានកំណត់ការទទួលបាន យើងនឹងពន្យល់អ្នកពីមូលហេតុអ្វី ។

### ស្នើសុំឲ្យពួកយើងកែតម្រូវព័ត៌មានរបស់អ្នក

- អ្នកអាចស្នើសុំឲ្យពួកយើងកែតម្រូវព័ត៌មានរបស់អ្នក បើអ្នកប្រាប់ពីមូលហេតុដែលអ្នកគិតថាវាមិនត្រឹមត្រូវ ឬមិនពេញលេញ ។
- យើងអាចនឹងថា "ទេ" ចំពោះសំណើរបស់អ្នក ប៉ុន្តែយើងនឹងប្រាប់អ្នកពីមូលហេតុជាលាយលក្ខណ៍អក្សរលឿនបំផុតតាមដែលអាចធ្វើបាន ។ ក្នុងករណីនេះ អ្នកអាចស្នើសុំឲ្យពួកយើងរក្សាច្បាប់ចម្លងនៃការមិនយល់ព្រមរបស់អ្នក (សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលអ្នកផ្តល់មកឲ្យយើង) ជាមួយកំណត់ត្រារបស់អ្នក ។

### ស្នើសុំឲ្យពួកយើងកម្រិតពីអ្វីដែលយើងប្រើប្រាស់ ឬចែករំលែក

- អ្នកអាចស្នើសុំឲ្យពួកយើងមិនប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នក ។ យើងនឹងតែងតែពិចារណាសំណើរបស់អ្នក ប៉ុន្តែយើងអាចថាទេ បើវាអាចប៉ះពាល់ដល់សមត្ថភាពរបស់យើងក្នុងការផ្តល់ការថែទាំឬសេវាកម្មដល់អ្នក ឬបើយើងមិនអាចធ្វើការកែប្រែក្នុងប្រព័ន្ធរបស់យើងបាន ។
- បើអ្នកបង់ប្រាក់ពេញថ្លៃចេញពីហោប៉ៅសម្រាប់សេវាកម្មឬវត្ថុ អ្នកអាចស្នើសុំពួកយើងពេលដែលអ្នកចូលមក មិនត្រូវចែករំលែកព័ត៌មានពីសេវាកម្មឬវត្ថុជាមួយនឹងគម្រោងសុខភាពរបស់អ្នក ។

ពួកយើងនឹងគោរពសំណើរបស់អ្នក លុះត្រាតែច្បាប់តម្រូវឲ្យពួកយើងចែករំលែកព័ត៌មាននោះជាមួយនឹងគម្រោងសុខភាពរបស់អ្នក ។

## សំណើទំនាក់ទំនងសម្ងាត់

- អ្នកអាចស្នើសុំឲ្យពួកយើងទាក់ទងទៅអ្នកតាមវិធីច្បាស់លាស់មួយ (ឧទាហរណ៍ ទូរស័ព្ទនៅផ្ទះឬនៅការិយាល័យ) ឬ ផ្ញើសំបុត្រទៅអាសយដ្ឋានផ្សេង ។ ពួកយើងនឹងព្យាយាមបំពេញតម្រូវការរបស់អ្នក ។

## ទទួលបានបញ្ជីអ្នកដែលទទួលព័ត៌មានរបស់អ្នក

- អ្នកអាចស្នើសុំបញ្ជី ("តារាង") នៃពេលវេលាដែលយើងបានចែករំលែកព័ត៌មានរបស់អ្នកជាមួយអង្គការខាងក្រៅឬបុគ្គលម្នាក់ៗដែលយើងបានចែករំលែកជាមួយ និងមូលហេតុ ។
- ពួកយើងនឹងបញ្ចូលរាល់ពេលវេលាដែលយើងបានចែករំលែកព័ត៌មានរបស់អ្នក លើកលែងតែសម្រាប់ការព្យាបាលរបស់អ្នក ការបង់ប្រាក់លើការព្យាបាលរបស់អ្នកឬប្រតិបត្តិការថែទាំសុខភាព និងពេលខ្លះទៀតពេលដែលយើងបានបញ្ចេញព័ត៌មានរបស់អ្នក (ដូចជាបើអ្នកស្នើសុំចែករំលែកវា និងបញ្ចេញ ពួកយើងបានប្រាប់អ្នក) ។

## ទទួលបានច្បាប់ចម្លងនៃកំណត់សម្គាល់នេះ

- អ្នកអាចស្នើសុំក្រដាសច្បាប់ចម្លងនៃកំណត់សម្គាល់នេះគ្រប់ពេលវេលា ។ ពួកយើងនឹងផ្តល់ជូនភ្លាម ។
- កំណត់សម្គាល់នេះក៏មាននៅលើ healthpartners.com និង parknicollet.com និងមាននៅរាល់ទីតាំងថែទាំរបស់ពួកយើង ។

## ដាក់ពាក្យបណ្តឹង បើអ្នកមានអារម្មណ៍ថាសិទ្ធិឯកជនរបស់អ្នកត្រូវបានរំលោភបំពាន

- អ្នកអាចប្តឹងដោយផ្ទាល់មកយើង បើអ្នកមានអារម្មណ៍ថាពួកយើងបានរំលោភបំពានសិទ្ធិឯកជនរបស់អ្នកដោយទាក់ទងមកយើងតាមព័ត៌មាននៅទំព័រចុងក្រោយនៃកំណត់សម្គាល់នេះ ។
- អ្នកក៏អាចដាក់ពាក្យបណ្តឹងទៅការិយាល័យសិទ្ធិស៊ីវិល ក្រសួងសុខភាព និងសេវាកម្មមនុស្សសហរដ្ឋអាមេរិក ។ ស្វែងរកព័ត៌មានទាក់ទងនៅ www.hhs.gov/ocr/privacy/hipaa/complaints/ ។
- ពួកយើងមិនប្រឆាំងនឹងអ្នកដោយសារអ្នកដាក់ពាក្យប្តឹង ។

## ជម្រើសរបស់អ្នក

**ក្នុងស្ថានភាពខ្លះ អ្នកមានជម្រើសបន្ថែមពីរបៀបដែលយើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នក ។** បើអ្នកពេញចិត្តស្ថានភាពដែលបានពណ៌នាខាងក្រោម សូមប្រាប់យើងឲ្យដឹង ។ ប្រាប់យើងពីអ្វីដែលអ្នកចង់ឲ្យយើងធ្វើ និងពួកយើងនឹង ធ្វើតាមការណែនាំរបស់អ្នក ស្របនឹងការធ្វើតាមច្បាប់ ។

### អ្នកអាចប្រាប់យើងមិនឲ្យធ្វើ៖

- ចែករំលែកព័ត៌មានរបស់អ្នកជាមួយគ្រួសារអ្នក មិត្តជិតស្និទ្ធ ឬអ្នកដទៃទៀតដែលបានចូលរួមក្នុងការថែទាំរបស់អ្នក ឬការបង់ប្រាក់សម្រាប់ការថែទាំរបស់អ្នក ។
- បញ្ចូលអ្នកក្នុងសៀវភៅរាយនាមអ្នកជម្ងឺរបស់យើងពេលដែលអ្នកត្រូវបានទទួលចូលក្នុងមន្ទីរពេទ្យរបស់យើង ។
- ទាក់ទងទៅអ្នកដើម្បីប្រមូលថវិកាគាំទ្របេសកកម្មរបស់យើង ។
- ចែករំលែកព័ត៌មានរបស់អ្នកជាមួយអ្នកដទៃសម្រាប់ការស្រាវជ្រាវសុខភាព ។ (ពួកយើងក៏អាចប្រើប្រាស់ព័ត៌មានរបស់អ្នកសម្រាប់ការស្រាវជ្រាវផ្ទាល់របស់យើង ដ៏រាបណាយើងធ្វើតាមច្បាប់ ។)

### យើងត្រូវតែទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នកមុននឹងយើង ៖

- ប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នកដើម្បីផ្សព្វផ្សាយផលិតផល ឬសេវាកម្មអង្គការផ្សេង ។
- ប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នកដើម្បីផ្សព្វផ្សាយផលិតផល ឬសេវាកម្មរបស់យើងផ្ទាល់ បើអង្គការផ្សេងបង់ប្រាក់ឲ្យយើងធ្វើដូចនេះ ឬបើផលិតផល ឬសេវាកម្មមិនជាប់ទាក់ទងនឹងសុខភាព ។
- លក់ ឬជួលព័ត៌មានរបស់អ្នកទៅអង្គការផ្សេង ។

## ភាពទទួលខុសត្រូវរបស់យើង

យើងការពារព័ត៌មានរបស់អ្នក ពីព្រោះភាពឯកជនរបស់អ្នកគឺមានសារៈសំខាន់ សម្រាប់យើង ហើយពីព្រោះវាជាច្បាប់ ។

- យើងត្រូវតែធ្វើតាមភាពទទួលខុសត្រូវ និងការអនុវត្តន៍ភាពឯកជន ដែលបានពណ៌នាក្នុងកំណត់សម្គាល់នេះ ។
- យើងត្រូវតែធ្វើឲ្យកំណត់សម្គាល់នេះមានសម្រាប់អ្នកនៅទីតាំងថែទាំអ្នកជម្ងឺរបស់យើង និងនៅលើគេហទំព័រ healthpartners.com និង parknicollet.com ។
- យើងអាចកែប្រែកំណត់សម្គាល់នេះ និងការកែប្រែទាំងនេះនឹងអនុវត្តលើរាល់ព័ត៌មានដែលយើងមានអំពីអ្នក ។ បើយើងធ្វើការកែប្រែច្រើន យើងនឹងដាក់កំណត់សម្គាល់ថ្មីនៅទីតាំងថែទាំអ្នកជម្ងឺរបស់យើង និងនៅលើអ៊ីនធឺណិត ។
- ពួកយើងនឹងឲ្យអ្នកដឹងភ្លាម បើមានការរំលោភបំពាន (ការប្រើប្រាស់ និងការចែករំលែកដោយគ្មានការអនុញ្ញាត) កើតឡើងដែលអាចធ្វើឲ្យមានបហានិភ័យដល់ភាពឯកជននៃព័ត៌មានរបស់អ្នក ។
- យើងនឹងមិនប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នក លើកលែងតែមានគ្រប់ដណ្តប់ក្នុងកំណត់សម្គាល់នេះ លុះត្រាតែអ្នកប្រាប់យើងថាអាចជាលាយលក្ខណ៍អក្សរ ។ អ្នកអាចកែប្រែចិត្តគ្រប់ពេលទាំងអស់ ។ ប្រាប់យើងជាលាយលក្ខណ៍អក្សរ បើអ្នកកែប្រែចិត្ត ។
- នៅពេលដែលច្បាប់តម្រូវឲ្យយើងទទួលបានការអនុញ្ញាតរបស់អ្នកជាលាយលក្ខណ៍អក្សរ មុននឹងយើងប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នក យើងនឹងធ្វើវា ។
- យើងនឹងសួរអ្នកពីការអនុញ្ញាតនេះពេលដំបូងដែលអ្នកក្លាយជាអ្នកជម្ងឺ និងយូរៗម្តងពេលក្រោយមកទៀត ។ វាជួយឲ្យយើងរៀបចំបានប្រសើរឡើងពីការថែទាំរបស់អ្នក ការបង់ប្រាក់សម្រាប់ការថែទាំរបស់អ្នក និងដំណើរការរបស់យើងដូចដែលបានពណ៌នាខាងក្រោម ។ បើអ្នកមិនចង់ផ្តល់ការអនុញ្ញាតដល់យើង អញ្ចឹងយើងមិនអាចគិតប្រាក់ពីគម្រោងសុខភាពរបស់អ្នកសម្រាប់សេវាកម្មរបស់អ្នក និងអាចត្រូវគិតប្រាក់អ្នកផ្ទាល់តែម្តង ។ យើងក៏មិនអាចសម្របសម្រួលការថែទាំរបស់អ្នក ។

## តើយើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកយ៉ាងដូចម្តេច?

យើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកដូចខាងក្រោម ៖

### ដើម្បីព្យាបាលអ្នក (ការព្យាបាល)

យើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកសម្រាប់ការព្យាបាលរបស់អ្នក និងដើម្បីបង្កើតបទពិសោធន៍ថែទាំដែលមានសុវត្ថិ-ភាព និងមានការសម្របសម្រួលច្រើនសម្រាប់អ្នក ។ នេះរាប់បញ្ចូលទាំងការចែករំលែកនៅក្នុងការរៀបចំការថែទាំសុខភាព ដូចជាវេជ្ជបណ្ឌិត និងបុគ្គលិកសុខាភិបាលពេទ្យដែលធ្វើការជាមួយគ្នាដើម្បីថែទាំអ្នក ។

មានវិធីជាច្រើនដើម្បីចែករំលែកព័ត៌មានរបស់អ្នកសម្រាប់ការព្យាបាល រួមមានតាមទូរស័ព្ទ ទូរសារ កំណត់ត្រាក្រដាស ការដោះប្តូរជាអេឡិចត្រូនិចដែលមានសុវត្ថិភាពជាមួយអ្នកផ្តល់ការថែទាំសុខភាពផ្សេងទៀត ។

***ឧទាហរណ៍៖*** *ជាគ្រូពេទ្យថែទាំបឋមរបស់អ្នក យើងប្រាប់គ្រូពេទ្យឯកទេសដែលកំពុងព្យាបាលអ្នកពីថ្នាំអ្វីដែលអ្នកប្រើប្រាស់ ដើម្បីជៀសវាងគ្រោះថ្នាក់នៃអន្តរកម្មថ្នាំ ។*

***ឧទាហរណ៍៖*** *យើងរំលឹកអ្នកពីការណាត់ជួបជាមួយយើងនៅពេលខាងមុខ ។*

***ឧទាហរណ៍៖*** *យើងអាចប្រើការដោះដូរជាអេឡិចត្រូនិចដើម្បីចែករំលែកព័ត៌មានរបស់អ្នកពីកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នកជាមួយអ្នកឯកទេសខាងក្រៅរបស់អ្នក ។*

សូមចំណាំថាយើងមិនត្រូវការការអនុញ្ញាតរបស់អ្នកដើម្បីចែករំលែកព័ត៌មានរបស់អ្នកពេលមានគ្រោះថ្នាក់ដល់ជីវិត បើអ្នកមិនអាចផ្តល់ការអនុញ្ញាតដល់យើងដោយសារស្ថានភាពរបស់អ្នក ។ អង្គការដែលគ្រប់ដណ្តប់ដោយកំណត់សម្គាល់នេះក៏មិនត្រូវការការអនុញ្ញាតរបស់អ្នកដើម្បីចែករំលែកព័ត៌មានរបស់អ្នកជាមួយគ្នា ខណៈពេលដែលវាជាគោលបំណងដែលបានអនុញ្ញាត ។

### ដើម្បីគិតប្រាក់សម្រាប់សេវាកម្មរបស់អ្នក (ការបង់ប្រាក់)

យើងអាចប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកដើម្បីបង់ប្រាក់ដល់អ្នកផ្តល់សេវាកម្ម និងអ្នកផ្សេងទៀតសម្រាប់ ការថែទាំដែលអ្នកបានទទួល ។

***ឧទាហរណ៍៖*** *យើងអាចផ្ញើព័ត៌មានអំពីសេវាកម្មដែលយើងបានផ្តល់ឲ្យអ្នកទៅគម្រោងសុខភាពរបស់អ្នក ដូច្នេះពួកគេនឹងបង់ប្រាក់ដល់យើងសម្រាប់សេវាកម្មទាំងនោះ ។*

***ឧទាហរណ៍៖*** *យើងអាចទាក់ទងទៅគម្រោងសុខភាពរបស់អ្នកដើម្បីដឹងថាសេវាកម្មត្រូវបានគ្របដណ្តប់មុននឹងយើងផ្តល់ការថែទាំនោះ ។*

## ដើម្បីដំណើរការអង្គការរបស់យើង (ដំណើរការការថែទាំសុខភាព)

យើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃបទពិសោធន៍ និងការថែទាំរបស់អ្នក និងគ្រប់គ្រងដំណើរការរបស់យើង ។

***ឧទាហរណ៍៖*** *យើងប្រើប្រាស់បរិមាណកំណត់នៃព័ត៌មានរបស់អ្នកដើម្បីជួយលើអាជ្ញាប័ណ្ណ និងការជឿជាក់ និងការវាយតម្លៃគុណភាព ។*

***ឧទាហរណ៍៖*** *យើងចែករំលែកបរិមាណកំណត់នៃព័ត៌មានរបស់អ្នកជាមួយអាជីវកម្មរួមគ្នា – អ្នកដែលជាដៃគូរបស់យើងក្នុងការផ្តល់សេវាកម្មជំនួសយើង ប៉ុន្តែមិនមែនជានិយោជក ឬសាខារបស់យើងទេ ។ ដៃគូទាំងនេះគឺតម្រូវដោយច្បាប់ ក្នុងការការពារព័ត៌មានរបស់អ្នកដូចដែលយើងធ្វើដែរ ។*

## តើយើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកយ៉ាងដូចម្តេចខ្លះទៀត?

យើងត្រូវបានអនុញ្ញាត ឬតម្រូវឲ្យចែករំលែកព័ត៌មានរបស់អ្នកក្នុងវិធីដែលទាក់ទងនឹងសុខភាពសាធារណៈ និងសកម្មភាពច្បាប់ ។ យើងត្រូវតែមានលក្ខខណ្ឌជាច្រើននៅក្នុងច្បាប់មុននឹងយើងអាចចែករំលែកព័ត៌មានរបស់អ្នកសម្រាប់គោលបំណងទាំងនេះ ។

### ធ្វើតាមច្បាប់

- យើងប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នក បើច្បាប់រដ្ឋ ឬសហព័ន្ធតម្រូវឲ្យធ្វើដូចនេះ ។

### ជួយក្នុងវិស័យសុខភាពសាធារណៈ និងបញ្ហាសុវត្ថិភាព

យើងចែករំលែកព័ត៌មានរបស់អ្នកជាមួយអាជ្ញាធរសុខភាពសាធារណៈ ឬទីភ្នាក់ងារដែលទទួលបានសិទ្ធិដទៃទៀតក្នុងស្ថានភាពខ្លះ ដូចជា ៖

- បង្ការជម្ងឺ
- ជួយក្នុងការហៅផលិតផលត្រឡប់មកវិញ
- រាយការណ៍ពីប្រតិកម្មមិនល្អរបស់ថ្នាំ
- រាយការណ៍ពីការសង្ស័យក្នុងការរំលោភបំពាន ព្រងើយកន្តើយ អំពើហឹង្សាក្នុងគ្រួសារ ឬបទឧក្រិដ្ឋនៅក្នុងទីតាំងថែទាំរបស់យើង
- បង្ការ ឬកាត់បន្ថយការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព ឬសុវត្ថិភាពនរណាម្នាក់

- ជួយក្នុងការត្រួតពិនិត្យប្រព័ន្ធសុខភាព ដូចជាការធ្វើសវនកម្ម ឬការស៊ើបអង្កេត
- ធ្វើតាមមុខងារពិសេសរបស់រដ្ឋាភិបាល ដូចជាយោធា សុវត្ថិភាពជាតិ សេវាកម្មការពារប្រធានាធិបតី និងការបង្ហាញពី មណ្ឌលកែតម្រូវ

## ឆ្លើយតបទៅនឹងសំណើបរិច្ចាគសរីរាង្គ និងជាលិកា

- យើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកដើម្បីជួយក្នុងការបរិច្ចាគសរីរាង្គ និងជាលិកា ។

## ធ្វើការជាមួយអ្នកពិនិត្យសុខាភិបាល ឬប្រធានរៀបចំបុណ្យសព

- យើងចែករំលែកព័ត៌មានរបស់អ្នកជាមួយអ្នកវិភាគសព អ្នកពិនិត្យសុខាភិបាល ឬប្រធានរៀបចំបុណ្យសព ។

## ដោះស្រាយសំណងរបស់អ្នកធ្វើការ

- យើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកសម្រាប់ការទាមទារសំណងអ្នកធ្វើការរបស់អ្នក ។

## ឆ្លើយតបទៅនឹងបណ្តឹង និងសកម្មភាពផ្លូវច្បាប់ផ្សេងៗ

- យើងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកសម្រាប់សកម្មភាពផ្លូវច្បាប់ផ្សេងៗ ឬដើម្បីឆ្លើយតបទៅនឹងដីកាតុលាការ ឬរដ្ឋបាល ឬដំណើរការផ្លូវច្បាប់ផ្សេងទៀត ។
- យើងអាចចែករំលែកព័ត៌មានរបស់អ្នកជាមួយមន្ត្រីប្រតិបត្តិច្បាប់ដែលទទួលបានសិទ្ធិ ។

## ជាមួយការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក

- បើយើងចង់ប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកតាមវិធីដែលមិនមាននៅក្នុងកំណត់សម្គាល់នេះ យើងតម្រូវឲ្យទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នកជាមុនសិន ។

## សម្រាប់ព័ត៌មាន សំណួរ ឬបណ្តឹងផ្សេងៗ

សូមនិយាយមកពួកយើងដែលនៅកន្លែងថែទាំរបស់អ្នក បើអ្នកមានសំណួរពីកំណត់សម្គាល់នេះ ។ អ្នកក៏អាចទាក់ទងមកពួកយើងតាមរយៈទូរស័ព្ទ

- បណ្តាញទាន់ហេតុការណ៍ HealthPartners Integrity និង Compliance លេខ 1-866-444-3493 ឬ បណ្តាញទាន់ហេតុការណ៍ Park Nicollet លេខ 1-855-246-PNHS (7647)

**តើអ្នកក៏ជាសមាជិកនៃគម្រោងសុខភាពដៃគូសុខភាពដែរទេ?**

ទទួលព័ត៌មានអំពីការអនុវត្តន៍ភាពឯកជនគម្រោងសុខភាពរបស់យើង និងសិទ្ធិឯកជននៃសមាជិកដោយទូរស័ព្ទទៅសេវាកម្មសមាជិកដៃគូសុខភាព តាមលេខទូរស័ព្ទ **952-967-5000** លេខទូរស័ព្ទឥតគិតថ្លៃ **800-883-2177** ឬ **952-883-5127 (TTY)** ។ អ្នកក៏អាចរកព័ត៌មាននោះបាននៅលើគេហទំព័រ **healthpartners.com** ។

កំណត់សម្គាល់នេះអនុវត្តលើអង្គការ និងអ្នកផ្តល់សេវាកម្មរបស់យើងទាំងអស់ * ៖

- Amery Regional Medical Center and Clinics
- Capitol View Transitional Care Center
- Group Health Plan
- HealthPartners
- HealthPartners Central Minnesota Clinics
- HealthPartners Dental Group and Clinics (រួមទាំងទន្តពេទ្យ WOW  ពេទ្យធ្មេញ River Valley និងទន្តពេទ្យ Stenberg)
- HealthPartners Hospice and Palliative Care
- HealthPartners Insurance Company
- HealthPartners Medical Group and Clinics
- Hudson Hospital & Clinics
- Hutchinson Health
- Integrated Home Care
- Lakeview Hospital
- North Suburban Family Physicians
- Park Nicollet Clinic
- Park Nicollet Health Care Products
- Park Nicollet Institute (រួមទាំងមជ្ឈមណ្ឌលជម្ងឺទឹកនោមផ្អែមអន្តរជាត)
- Park Nicollet Melrose Institute
- Park Nicollet Methodist Hospital
- Physicians Neck & Back Clinics
- Regions Hospital
- RHSC
- RiverWay Clinics
- Stillwater Medical Group and Clinics
- TRIA Orthopaedic Center
- virtuwell®
- Western Wisconsin Emergency Medical Services/Unity Ambulance
- Westfields Hospital
- បុគ្គលិកសុខាភិបាលដែលផ្តល់សេវាកម្មនៅក្នុងអង្គការណាមួយនៅក្នុងបញ្ជីនេះ
- កម្មវិធី និងសេវាកម្មឯកទេសដែលផ្តល់ដោយអង្គការណាមួយនៅក្នុងបញ្ជីនេះ
- អ្នកផ្តល់សេវាកម្ម ឬអ្នកចុះកុងត្រាឯករាជ្យដែលចូលរួមក្នុងការរៀបចំការថែទាំសុខភាពនៅក្នុងមន្ទីរពេទ្យរបស់យើង ។

** បញ្ជីនេះអាចប្រែប្រួលពីពេលមួយទៅពេលមួយ ដូចដែលអង្គការយើងប្រែប្រួល និងលូតលាស់ ។ យើងនឹងធ្វើបច្ចុប្បន្នភាពបញ្ជីនៅក្នុងកំណត់សម្គាល់នេះដែលនឹងដាក់នៅលើគេហទំព័រ healthpartners.com និង parknicollet.com ។*

# សេចក្តីថ្លែងការណ៍អំពីការមិនរើសអើងចំពោះអ្នកជំងឺ

## ទំនួលខុសត្រូវរបស់យើង៖

យើងអនុវត្តតាមច្បាប់សិទ្ធិស៊ីវិលសហព័ន្ធ។ យើងមិនរើសអើងដោយផ្អែកលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ អាយុ ពិការភាព ឬភេទឡើយ។ យើងរួមបញ្ចូលមនុស្សគ្រប់រូប ឬមិនប្រព្រឹត្តចំពោះពួកគេដោយខុសៗគ្នា ព្រោះតែពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ អាយុ ពិការភាព ឬភេទ រួមទាំងអត្តសញ្ញាណយេនឌ័ររបស់ពួកគេឡើយ។

- យើងជួយមនុស្សពិការឱ្យប្រាស្រ័យទាក់ទងជាមួយយើង។ ការជួយនេះគឺឥតគិតថ្លៃ។ វារួមទាំង៖
  - អ្នកបកប្រែភាសាសញ្ញាដែលមានគុណវុឌ្ឍគ្រប់គ្រាន់
  - ព័ត៌មានជាលាយលក្ខណ៍អក្សរជាទម្រង់ផ្សេងៗ ដូចជាទម្រង់អក្សរពុម្ពធំ អូឌីយ៉ូ និងជាអេឡិចត្រូនិចដែលអាចចូលប្រើបាន
- យើងផ្តល់សេវាកម្មផ្សេងៗសម្រាប់មនុស្សដែលមិនចេះនិយាយភាសាអង់គ្លេស ឬអ្នកដែលពិបាកនិយាយភាសាអង់គ្លេស។ សេវាកម្មទាំងនេះគឺឥតគិតថ្លៃ។ សេវាកម្មទាំងនេះរួមមាន៖
  - អ្នកបកប្រែដែលមានគុណវុឌ្ឍគ្រប់គ្រាន់
  - ព័ត៌មានជាលាយលក្ខណ៍អក្សរជាភាសាផ្សេងៗ

## សម្រាប់ជំនួយភាសា ឬការប្រាស្រ័យទាក់ទង៖

ទូរស័ព្ទទៅលេខ 1-844-363-8974 បើអ្នកត្រូវការជំនួយភាសា ឬការប្រាស្រ័យទាក់ទងដទៃ។

## ប្រសិនបើអ្នកមានសំណួរផ្សេងៗអំពីគោលការណ៍មិនរើសអើងរបស់យើង៖

ចូរទាក់ទងអ្នកសម្របសម្រួលសិទ្ធិស៊ីវិល តាមលេខ 1-844-363-8732 ឬ integrityandcompliance@healthpartners.com។

## ដើម្បីដាក់ពាក្យបណ្ដឹងតវ៉ាពីភាពមិនសុខចិត្ត៖

ប្រសិនបើអ្នកជឿថា យើងមិនបានផ្ដល់សេវាកម្មទាំងនេះ ឬបានរើសអើងប្រឆាំងអ្នកព្រោះតែពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ អាយុ ពិការភាព ឬភេទរបស់អ្នក អ្នកអាចដាក់បណ្ដឹងសារទុក្ខដោយទាក់ទងអ្នកសម្របសម្រួលសិទ្ធិស៊ីវិល តាមលេខ 1-844-363-8732, integrityandcompliance@healthpartners.com ឬ Civil Rights Coordinator, Office of Integrity and Compliance, MS 21103K, 8170 33rd Ave S., Bloomington, MN 55425

អ្នកក៏អាចដាក់បណ្ដឹងសិទ្ធិស៊ីវិលជាមួយក្រសួងសុខាភិបាល និងសេវាមនុស្សសហរដ្ឋអាមេរិក ការិយាល័យសម្រាប់សិទ្ធិស៊ីវិល ជាអេឡិចត្រូនិចតាមរយៈផតថលបណ្ដឹងរបស់ការិយាល័យសម្រាប់បណ្ដឹងស៊ីវិល ដែលអាចរកបានតាម https://ocrportal.hhs.gov/ocr/portal/lobby.jsf ឬតាមសំបុត្រប្រៃសណីយ៍ ឬទូរស័ព្ទនៅ៖

U.S. Department of Health and Human Services
Room 509F, HHH Building
200 Independence Avenue SW
Washington, DC 20201
1-800-368-1019, 800-537-7697 (TDD)

| | |
|---|---|
| Español *(Spanish)* | ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-844-363-8974. |
| Hmoob *(Hmong)* | LUS CEEV: Yog tias koj hais lus Hmoob, cov kev pab txog lus, muaj kev pab dawb rau koj. Hu rau 1-844-363-8974. |
| Tiếng Việt *(Vietnamese)* | CHÚ Ý: Nếu bạn nói Tiếng Việt, có các dịch vụ hỗ trợ ngôn ngữ miễn phí dành cho bạn. Gọi số 1-844-363-8974. |
| Af Soomaali *(Somali)* | OGAYSIIS: Haddii aad ku hadasho afka soomaaliga, Waxaa kuu diyaar ah caawimaad xagga luqadda ah oo bilaash ah. Fadlan soo wac 1-844-363-8974. |

| | |
|---|---|
| 繁體中文<br>*(Chinese)* | 注意：如果您使用繁體中文，您可以免費獲得語言援助服務。請致電 1-844-363-8974。 |
| Русский<br>*(Russian)* | ВНИМАНИЕ: Если вы говорите на русском языке, то вам доступны бесплатные услуги перевода. Звоните 1-844-363-8974. |
| ພາສາລາວ<br>*(Laotian)* | ໂປດຊາບ: ຖ້າວ່າ ທ່ານເວົ້າພາສາ ລາວ, ການບໍລິການຊ່ວຍເຫຼືອດ້ານພາສາ, ໂດຍບໍ່ເສັຽຄ່າ, ແມ່ນມີພ້ອມໃຫ້ທ່ານ. ໂທຣ 1-844-363-8974. |
| Deutsch<br>*(German)* | ACHTUNG: Wenn Sie Deutsch sprechen, stehen Ihnen kostenlos sprachliche Hilfsdienstleistungen zur Verfügung. Rufnummer: 1-844-363-8974. |
| العربية<br>*(Arabic)* | ملحوظة: إذا كنت تتحدث اذكر اللغة، فإن خدمات المساعدة اللغوية تتوافر لك بالمجان. اتصل برقم 1-844-363-8974. |
| Français<br>*(French)* | ATTENTION : Si vous parlez français, des services d'aide linguistique vous sont proposés gratuitement. Appelez le 1-844-363-8974. |
| 한국어<br>*(Korean)* | 주의: 한국어를 사용하시는 경우, 언어 지원 서비스를 무료로 이용하실 수 있습니다. 1-844-363-8974. |
| Tagalog<br>*(Tagalog)* | PAUNAWA: Kung nagsasalita ka ng Tagalog, maaari kang gumamit ng mga serbisyo ng tulong sa wika nang walang bayad. Tumawag sa 1-844-363-8974. |
| Oroomiffa<br>*(Cushite [Oromo])* | XIYYEEFFANNAA: Afaan dubbattu Oroomiffa, tajaajila gargaarsa afaanii, kanfaltiidhaan ala, ni argama. Bilbilaa 1-844-363-8974. |
| አማርኛ<br>*(Amharic)* | ማስታወሻ: የሚናገሩት ቋንቋ ኣማርኛ ከሆነ የትርጉም እርዳታ ድርጅቶች፣ በነጻ ሊያግዝዎት ተዘጋጀተዋል፡ ወደ ሚከተለው ቁጥር ይደውሉ 1-844-363-8974. |

| | |
|---|---|
| ကညီ<br>*(Karen)* | ဟ်သူၣ်ဟ်သး– နမ့ၢ်ကတိၤ ကညီ ကျိာ်အယိ နမ့ၢ်န့ၢ် ကျိာ်အတၢ်မၤစၢၤလၢ တလၢာ်ဘူၣ်လၢာ်စ့ၤ နီတမံၤဘၣ်သ့ၣ်လီၤ. ကိး 1-844-363-8974ၣ |
| ខ្មែរ<br>*(Mon- Khmer, Cambodian)* | ប្រយ័ត្ន៖ បើសិនជាអ្នកនិយាយ ភាសាខ្មែរ, សេវាជំនួយផ្នែកភាសា ដោយមិនគិតឈ្នួល គឺអាចមានសំរាប់បំរើអ្នក។ ចូរ ទូរស័ព្ទ 1-844-363-8974. |
| Deitsch<br>*(Pennsylvania Dutch)* | Wann du Deitsch schwetzscht, kannscht du mitaus Koschte ebber gricke, ass dihr helft mit die englisch Schprooch. Ruf selli Nummer uff: 1-844-363-8974. |
| Polski<br>*(Polish)* | UWAGA: Jeżeli mówisz po polsku, możesz skorzystać z bezpłatnej pomocy językowej. Zadzwoń pod numer 1-844-363-8974. |
| हिंदी<br>*(Hindi)* | ध्यान दें: यदि आप हिंदी बोलते हैं तो आपके लिए मुफ्त में भाषा सहायता सेवाएं उपलब्ध हैं। 1-844-363-8974. |
| Shqip<br>*(Albanian)* | KUJDES: Nëse flitni shqip, për ju ka në dispozicion shërbime të asistencës gjuhësore, pa pagesë. Telefononi në 1-844-363-8974. |
| ကြမာနနန<br>*(Burmese)* | သတိပြုရန် - အကယ်၍ သင်သည် မြန်မာစကား ကို ပြောပါက၊ ဘာသာစကား အကူအညီ၊ အခမဲ့၊ သင့်အတွက် စီစဉ်ဆောင်ရွက်ပေးပါမည်။ ဖုန်းနံပါတ် 1-844-363-8974. |

HealthPartners®

23668 (11/18) © 2018 HealthPartners Khmer